**ក្រសួងទេសចរណ៍នៃព្រះរាជាណាចក្រកម្ពុជា និង អង្គការពលកម្មអន្តរជាតិ**
**រួមគ្នាគាំទ្រការលើកកំពស់គោលនយោបាយ"សុវត្ថិភាពកុមារ"ក្នុងវិស័យទេសចរណ៍**
**ដើម្បីបង្ការទប់ស្កាត់ការជួញដូរកុមារនិងស្ត្រី**

**ការលើកកំពស់ឱ្យមានបរិយាកាសសុវត្ថិភាពជាងមុនក្នុងផ្នែកឧស្សាហកម្មទេសចរណ៍ - និយោជក កម្មករ និង មន្ត្រី បុគ្គលិក របស់ស្ថាប័ន រដ្ឋាភិបាលនិងអង្គការក្រៅរដ្ឋាភិបាលដែលពាក់ព័ន្ធ ទទួលបាននូវការបណ្តុះបណ្តាលស្តីពីវិធានការទប់ទល់ប្រឆាំងនឹងការជួញដូរ**

**ថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០០៥**

## សំរាប់ការផ្សព្វផ្សាយបន្ទាន់

ភ្នំពេញ- នៅថ្ងៃនេះ កសួងទេសចរណ៍ បានប្រារព្ធធ្វើពិធីប្រកាសចាប់ផ្តើមដំណើរគំរោងកម្មវិធីសកម្មភាពថ្មីនិង ជាក់លាក់មួយចំនួនដែលបានរៀបចំឡើង ដើម្បីពង្រឹងបន្ថែមលើផ្នែកទេសចរណ៍ដែលជាកម្លាំងវិជ្ជមានមួយក្នុងការអភិវឌ្ឍន៍ ដើម្បីជួយបង្ការទប់ស្កាត់ពីស្ថានភាពនៃការរំលោភបំពាននានា ដែលកើតមានពីការអភិវឌ្ឍន៍ក្នុងវិស័យនេះ។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួងកិច្ចការនារី ក៏បានចូលរួម ក្នុងការជួយសំរបសំរួលផងដែរនូវកិច្ចខិតខំប្រឹងប្រែងនេះ។

យុទ្ធនាការបង្កើនការយល់ដឹងជាសាធារណៈ ស្តីពី "សុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍" នឹងត្រូវចាប់ដំណើរការនៅទូទាំងប្រទេស។ ក្រុមគោលដៅដ៏សំខាន់សំរាប់យុទ្ធនាការនៃការគាំទ្រនេះ គឺជាភ្ញៀវទេសចរក្នុងស្រុកចំនួន ៤,២៥ លាននាក់ដែលមានចំនួន ៤ដងច្រើនជាងភ្ញៀវទេសចរអន្តរជាតិ ។ អ្នកទទួលផ្ទាល់គឺជាពលរដ្ឋក្មេងៗដែលកំពុងសំរុករកការងារធ្វើក្នុងវិស័យឧស្សាហកម្មដែលរីកចំរើន ។

ដោយមានការគាំទ្រពីគំរោងអនុតំបន់ទន្លេមេគង្គប្រឆាំងការជួញដូរពលកម្មកុមារ និងស្ត្រី របស់អង្គការពលកម្មអន្តរជាតិ (TICW Project) ក្រសួងទេសចរណ៍កំពុងរៀបចំចងក្រងនូវផែនការយុទ្ធសាស្ត្រ គោលការណ៍ប្រត្តិបត្តិ និង ឯកសារបណ្តុះបណ្តាលសំរាប់ផ្សព្វផ្សាយពីកម្មវិធី "សុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍" របស់រាជរដ្ឋាភិបាលកម្ពុជា។

គំរោងអនុតំបន់ទន្លេមេគង្គប្រឆាំងការជួញដូរពលកម្មកុមារនិងស្ត្រី (TICW Project) នេះ កំពុងងគាំទ្រដល់ការបណ្តុះ-បណ្តាលនៅកន្លែងការងារថ្នាក់មូលដ្ឋាន នៅក្នុងខេត្តសៀមរាប តាមរយៈមន្ទីរទេសចរណ៍ខេត្តសៀមរាប នៅក្រុងព្រះសីហនុ តាមរយៈមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនិតិសម្បទាក្រុង និងនៅទីក្រុងភ្នំពេញ តាមរយៈ មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនិតិសម្បទារាជធានិ។ ខេត្ត-ក្រុង ទាំងបីនេះ សុទ្ធតែធ្លាប់បានទទួលនូវកំណើន ភ្ញៀវទេសចរជារៀងរាល់ឆ្នាំ។

សកម្មភាពរបស់គំរោង នឹងផ្តោតទៅលើការប្រយុទ្ធប្រឆាំងនឹងការជួញដូរ ដើម្បីកេងប្រវ័ញ្ចកំលាំងពលកម្ម និង ផ្លូវភេទនៅតាមកន្លែងសេវាកម្ម និងឧស្សាហកម្មទេសចរណ៍ខ្លះៗដែលងាយរងគ្រោះបំផុត ដូចជាតាមភោជនីយដ្ឋាន សណ្ឋាគារ ផ្ទះសំណាក់និងកន្លែងកំសាន្តមួយចំនួន ដែលជួនកាលមានអ្នករកការងារអោយធ្វើ និយោជក និងអ្នកធ្វើការជាមួយគ្នា បានឆ្លៀតកេងប្រវ័ញ្ចលើយុវជនក្មេងៗបាន។ និយោជក និងកម្មករ នឹងទទួលបាននូវការបណ្តុះបណ្តាលពីវិធី ដែលអាចជៀសវាងពីស្ថានភាពនៃការកេងប្រវ័ញ្ចនានានៅក្នុងកន្លែងធ្វើការងារ។ ក្រសួងទេសចរណ៍ និងក្រសួងការងារនិង បណ្តុះបណ្តាលវិជ្ជាជីវៈ នឹងធ្វើការរួមគ្នាដើម្បីត្រួតពិនិត្យមើលកន្លែងធ្វើការងារទាំងអស់នោះ។

ការជួយឧបត្ថម្ភគាំទ្រដោយផ្ទាល់ខ្លះទៀត នឹងត្រូវបានផ្តល់ដល់អ្នកចំណាកស្រុកស្វែងរកការងារធ្វើវ័យក្មេង ក្នុងតំបន់គោលដៅនានា ដើម្បីអោយពួកគេអាចជៀសផុតពីស្ថានភាពនៃការកេងប្រវ័ញ្ចទាំងនោះ។


**សំរាប់ពតិមានបន្ថែម សូមទំនាក់ទំនងៈ**

**លោក ហោ សារុន**
អគ្គនាយករងរដ្ឋបាល និងហិរញ្ញវត្ថុនៃក្រសួងទេសចរណ៍
និងជា ប្រធានក្រុមលេខាធិការដ្ឋាន គ.ស.ក.ទ
ទូរស័ព្ទៈ +៨៥៥ ២៣ ២១៣ ៧៤១
ទូរសារៈ +៨៥៥ ២៣ ២២០ ៧០៤
អ៊ីម៉ែលៈ horsarun@yahoo.com

**លោក ឃ្លាំង រីម**
អ្នកសំរបសំរួលគំរោងថ្នាក់ជាតិ
គំរោង ILO IPEC TICW
ទូរស័ព្ទៈ + ៨៥៥ ១២ ៩២៨ ៩៧១/ ២៣ ២២០ ៨១៧
ទូរសារៈ + ៨៥៥ ២៣ ២២១ ៩៣៦
អ៊ីម៉ែលៈ Rimiloipeccam@online.com.kh


សូមមើល Website របស់គំរោងអនុតំបន់ទន្លេមេគង្គប្រឆាំងការជួញដូរពលកម្មកុមារនិងស្ត្រី :

**www.childtrafficking.net**